អាជ្ញាធរមីន

C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍

# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅខែសីហា ឆ្នាំ២០២៣

**សារតារ**

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

## ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### 1- ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែសីហា ឆ្នាំ២០២៣

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែសីហា ឆ្នាំ២០២៣ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចំនួន ៦៥.០៣១នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.១៨០នាក់(៧៩%) និងស.ផ.ស. ១៣.៨៥១នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩.៨២២នាក់(៣០%) របួស ៣៦.១២៣នាក់(៥៦%) និងពិការអវយវៈ ៩.០៨៦នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២.៦៧០នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.១១១នាក់(៩%) ស្ត្រី ៤.៧៩៤នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩៣នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)

### 2- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពីខែមករា ដល់ខែសីហា ឆ្នាំ២០២៣

ចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០២៣ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចំនួន ២៣ករណី។ តួលេខនេះបានថយចុះ ១៨% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២២ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៨ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៣ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១៣ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ១០ករណី។

### 3- ជនរងគ្រោះពីខែមករា ដល់ខែសីហា ឆ្នាំ២០២៣

តួលេខជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០២៣ មានចំនួន ២៦នាក់។ តួលេខនេះបានថយចុះ ៣៥% បើប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២២ ដែលមានជនរងគ្រោះចំនួន ៤០នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ២៦នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១៣នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១៣នាក់
- ជនរងគ្រោះស្លាប់ ៤នាក់ របួស ១៤នាក់ និងពិការអវយវៈ ៨នាក់
- ជនរងគ្រោះជាបុរស ២០នាក់ ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៥នាក់ និងស្ត្រី ១នាក់។

## 4- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែសីហា ឆ្នាំ២០២៣

នៅខែសីហា ឆ្នាំ២០២៣ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣ករណី ជាឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ដែលបានកើតឡើងនៅខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង និង ខេត្តរតនគិរី។ តួលេខនេះមានការកើនឡើង ១០០% បើប្រៀបធៀបជាមួយនឹងខែសីហា ឆ្នាំ២០២២ ដែលមិនមានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទេ។

ព័ត៌មានពីតំបន់គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែសីហា ឆ្នាំ២០២៣ ដូចខាងក្រោម៖

- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន កើតឡើងនៅលើដីចម្ការ ១ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន កើតឡើងនៅលើផ្លូវលំ ១ករណី
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន កើតឡើងនៅលើដីពុំមានការប្រើប្រាស់ ១ករណី

## 5- ជនរងគ្រោះក្នុងខែសីហា ឆ្នាំ២០២៣

នៅខែសីហា ឆ្នាំ២០២៣ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣នាក់។ តួលេខនេះបានកើនឡើង ១០០% បើប្រៀបធៀបនឹងខែសីហា ឆ្នាំ២០២២ ដែលមិនមានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទេ។

ក្នុងចំណោមជនរងគ្រោះចំនួន ៣នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ៣នាក់
- ជនរងគ្រោះពិការអវយវៈ ១នាក់ របួស ១នាក់ និងស្លាប់ ១នាក់
- ជនរងគ្រោះជាបុរស ២នាក់ និងជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ១នាក់
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖
  - ការឃ្វាលសត្វ ១នាក់
  - ការធ្វើដំណើរ ១នាក់
  - ការធ្វើសកម្មភាពយោធា ១នាក់។

## 6- ផលប៉ះពាល់នៃតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២២ ដល់ខែសីហា ឆ្នាំ២០២៣ (ជនរងគ្រោះ ៦៧នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៣% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៧២% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៤% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

## ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងខែសីហា ឆ្នាំ២០២៣
## ឧប្បត្តិហេតុ ៣ករណី ជនរងគ្រោះ ៣នាក់




Produced by CMVIS, Sep 2023

ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

## របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ2020 ដល់ខែសីហា ឆ្នាំ2023

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2020** | **3** | **3** | **6** | **7** | **13** | **6** | **7** | **7** | **3** | **0** | **5** | **5** | **65** |
| *ការបូកបណ្តាក់ ឆ្នាំ2020* | *3* | *6* | *12* | *19* | *32* | *38* | *45* | *52* | *55* | *55* | *60* | *65* | |
| **2021** | **6** | **5** | **2** | **8** | **5** | **0** | **4** | **3** | **1** | **8** | **0** | **2** | **44** |
| *ការបូកបណ្តាក់ ឆ្នាំ2021* | 6 | 11 | 13 | 21 | 26 | 26 | 30 | 33 | 34 | 42 | 42 | 44 | |
| *ការប្រែប្រួលភាគរយ 2020 ធៀប 2021* | 100 | 83 | 8 | 11 | -19 | -32 | -33 | -37 | -38 | -24 | -30 | -32 | |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2021* | 5 | 4 | 5 | -1 | 0 | 1 | -4 | -3 | -1 | -8 | 0 | -1 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2021* | 83 | 80 | 250 | -13 | 0 | 100 | -100 | -100 | -100 | -100 | 0 | -50 | |
| *ការបូកបណ្តាក់ ឆ្នាំ2022* | ***11*** | ***20*** | ***27*** | ***34*** | ***39*** | ***40*** | ***40*** | ***40*** | ***40*** | ***40*** | ***40*** | ***41*** | |
| *ការប្រែប្រួលភាគរយ 2021 ធៀប 2022* | 83 | 82 | 108 | 62 | 50 | 54 | 33 | 21 | 18 | -5 | -5 | -7 | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | | | | | **26** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2022* | -8 | -4 | -3 | -7 | 2 | 1 | 2 | 3 | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2022* | -73 | -44 | -43 | -100 | 40 | 100 | 100 | 100 | | | | | |
| *ការបូកបណ្តាក់ ឆ្នាំ2023* | ***3*** | 8 | ***12*** | 12 | ***19*** | ***21*** | ***23*** | ***26*** | | | | | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | | | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀតនឹងស្រាវជ្រាវឲ្យទាន់ពេលវេលា ដែលជាផ្នែកមួយនៃដំណើរការប្រមូលទិន្នន័យ



## ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ2022 ដល់ខែសីហា ឆ្នាំ2023

### រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ2022 និងឆ្នាំ2023

| | មករា22 | កុម្ភៈ22 | មីនា22 | មេសា22 | ឧសភា22 | មិថុនា22 | កក្កដា22 | សីហា22 | កញ្ញា22 | តុលា22 | វិច្ឆិកា22 | ធ្នូ22 | សរុប2022 | មករា23 | កុម្ភៈ23 | មីនា23 | មេសា23 | ឧសភា23 | មិថុនា23 | កក្កដា23 | សីហា23 | កញ្ញា23 | តុលា23 | វិច្ឆិកា23 | ធ្នូ23 | សរុប2023 | សរុប | ការបូកបណ្តាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្តាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2022-2023** | | | |
| ព្រះវិហារ | 6 | 0 | 2 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **12** | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **2** | **14** | 14 | 20.9 | 21 |
| បាត់ដំបង | 2 | 0 | 3 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | **7** | 0 | 0 | 0 | 0 | 2 | 0 | 0 | 1 | 0 | 0 | 0 | 0 | **3** | **10** | 24 | 14.9 | 36 |
| ឧត្តរមានជ័យ | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | **3** | 0 | 1 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | **7** | 31 | 10.4 | 46 |
| កំពង់ធំ | 1 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **5** | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **6** | 37 | 9 | 55 |
| រតនៈគីរី | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 3 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | **5** | 42 | 7.5 | 63 |
| ពោធិសាត់ | 1 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **5** | 47 | 7.5 | 70 |
| ស្វាយរៀង | 0 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **5** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **5** | 52 | 7.5 | 78 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 3 | 0 | 1 | 0 | 0 | 0 | 0 | 0 | **4** | **4** | 56 | 6 | 84 |
| សៀមរាប | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **3** | 59 | 4.5 | 88 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | **2** | **2** | 61 | 3 | 91 |
| ក្រចេះ | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **2** | 63 | 3 | 94 |
| ព្រះសីហនុ | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 64 | 1.5 | 96 |
| តាកែវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 65 | 1.5 | 97 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 66 | 1.5 | 99 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 67 | 1.5 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| កណ្តាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| មណ្ឌលគីរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 67 | 0 | 100 |
| សរុប | 11 | 9 | 7 | 7 | 5 | 1 | 0 | 0 | 0 | 0 | 0 | 1 | **41** | 3 | 5 | 4 | 0 | 7 | 2 | 2 | 3 | 0 | 0 | 0 | 0 | **26** | **67** | | | |



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែសីហា ឆ្នាំ2023

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | ព្រះវិហារ | 12 | 2 | **14** | 14 |
| 2 | បាត់ដំបង | 3 | 7 | **10** | 24 |
| 3 | ឧត្តរមានជ័យ | 6 | 1 | **7** | 31 |
| 4 | កំពង់ធំ | 0 | 6 | **6** | 37 |
| 5 | ពោធិសាត់ | 4 | 1 | **5** | 42 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែសីហា ឆ្នាំ2023

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 12 | 2 | **14** | 14 |
| 2 | សំឡូត | បាត់ដំបង | 1 | 4 | **5** | 19 |
| 3 | វាលវែង | ពោធិសាត់ | 4 | 1 | **5** | 24 |
| 4 | អូរយ៉ាដាវ | រតនៈគិរី | 1 | 4 | **5** | 29 |
| 5 | ស្វាយរៀង | ស្វាយរៀង | 0 | 5 | **5** | 34 |
| 6 | អន្លង់វែង | ឧត្តរមានជ័យ | 3 | 1 | **4** | 38 |
| 7 | បារាយណ៍ | កំពង់ធំ | 0 | 4 | **4** | 42 |
| 8 | អូរជ្រៅ | បន្ទាយមានជ័យ | 2 | 0 | **2** | 44 |
| 9 | ថ្មពួក | បន្ទាយមានជ័យ | 2 | 0 | **2** | 46 |
| 10 | រតនៈមណ្ឌល | បាត់ដំបង | 0 | 2 | **2** | 48 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ

ពីខែមករា ឆ្នាំ2022 ដល់ខែសីហា ឆ្នាំ2023

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 6 | 1 | **7** | 7 |
| 2 | សង្ហារ | ស្វាយរៀង | ស្វាយរៀង | 0 | 5 | **5** | 12 |
| 3 | គគីរធំ | បារាយណ៍ | កំពង់ធំ | 0 | 4 | **4** | 16 |
| 4 | យ៉ាទុង | អូរយ៉ាដាវ | រតនៈគិរី | 0 | 4 | **4** | 20 |
| 5 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្តរមានជ័យ | 2 | 1 | **3** | 23 |
| 6 | ជាំក្សាន្ត | ជាំក្សាន្ត | ព្រះវិហារ | 2 | 1 | **3** | 26 |
| 7 | សំរិល | សំឡូត | បាត់ដំបង | 1 | 2 | **3** | 29 |
| 8 | អន្លង់រាប | វាលវែង | ពោធិសាត់ | 2 | 1 | **3** | 32 |
| 9 | ថ្មដា | វាលវែង | ពោធិសាត់ | 2 | 0 | **2** | 34 |
| 10 | ឆ្នាល់មាន់ | គាស់ក្រឡ | បាត់ដំបង | 1 | 1 | **2** | 36 |

# ការឆ្លុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេល: មករា ឆ្នាំ2022 - សីហា ឆ្នាំ2023

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍: 67










## ការឆ្លុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












អំឡុងពេលៈ ខែមករា ឆ្នាំ2022 - ខែសីហា ឆ្នាំ2023

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍: 67

## សកម្មភាពដែលបណ្តាលឲ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ

| បុរស | ស្ត្រី | ក្មេង | សរុប |
| --- | --- | --- | --- |
| 48 | 2 | 17 | 67 |




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្តាលឲ្យផ្ទុះមីន

32




### សកម្មភាពដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

35




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឲ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

